# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....០៤...សរន...........

# សារាចរ

## ស្តីពី

## វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព "ក្មេងទំនើង"

កន្លងមក ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ បានខិតខំអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ទទួលបានលទ្ធផលការងារល្អប្រសើរ ជាពិសេស ធានាបានសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងភាពសុខសាន្តជូនប្រជាពលរដ្ឋ ។ ជាក់ស្តែង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សកម្មភាពបទល្មើសនានា បានថយចុះ គួរឱ្យកត់សម្គាល់ ។

ដោយឡែក នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានពិនិត្យឃើញថា សកម្មភាពនៃ "ក្មេងទំនើង" បានបន្តរីករាលដាលក្រោមរូបភាពផ្សេងៗរហូតដល់ទីជនបទ ។ ក្មេងទំនើងទាំងនេះ តែងបានប្រមូលផ្តុំគ្នាជាក្រុម ធ្វើសកម្មភាពអុកឡុកដល់សង្គមតាមតែអំពើចិត្តដោយមិនញញើត ឬគោរពកោតខ្លាចច្បាប់រដ្ឋ ឬក៏សមត្ថកិច្ចអ្វីឡើយ ដូចជាបង្កការអុកឡុករំខាននៅតាមទីកន្លែងសាធារណៈ នៅតាមសាលារៀន នៅតាមពិធីជប់លៀង រាំកំសាន្តនានាធ្វើការគំរាមកំហែងដល់សាធារណជន ជិះរថយន្ត ឬម៉ូតូប្រជេញគ្នាតាមផ្លូវសាធារណៈឬជិះម៉ូតូបង្ហោះ ។ល។ ហើយពេលខ្លះ ក្មេងទំនើងទាំងនេះ បានធ្វើសកម្មភាពឈានទៅដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងសកម្មភាពល្មើសផ្សេងៗទៀត បណ្តាលឱ្យប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ ។

ដើម្បីគ្រប់គ្រងស្ថានការណ៍នេះ និងចាត់វិធានការបង្ការទប់ស្កាត់និងបង្ក្រាបសកម្មភាព របស់ក្មេងទំនើងល្មើសទាំងនេះ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ក្នុងគោលដៅធានារក្សា បរិយាកាសសង្គមល្អប្រសើរ ប្រកបដោយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ភាពសុខសាន្ត និងសេចក្តីថ្លៃថ្នូរ រាជរដ្ឋាភិបាល សូមដាក់ចេញវិធានការដូចខាងក្រោម :

១- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងអប់រំយុវជន និងកីឡា រដ្ឋបាលរាជធានី-ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ឬចាត់វិធានការគ្រប់គ្រងមុខសញ្ញា និងសកម្មភាពនៃក្រុមក្មេងទំនើង ដែលបង្កការអុកឡុករំខានដល់ប្រជាពលរដ្ឋ និង ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវមានវិធានការអប់រំ វិធានការរដ្ឋបាល ឬវិធានការច្បាប់ ដែលចាំបាច់និងសមស្រប ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអោយមានប្រសិទ្ធភាព ។

២ - អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់វិធានការជាក់ស្តែងនានា នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ធ្វើអន្តរាគមន៍បង្ការទប់ស្កាត់និងបង្ក្រាបឱ្យបានទាន់ពេលវេលា នូវរាល់សកម្មភាពអុកឡុកបង្កការប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសកម្មភាពល្មើស របស់ក្រុមក្មេងទំនើងនៅតាមមូលដ្ឋាននីមួយៗ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ គណៈបញ្ជាការឯកភាពរាជធានី ខេត្ត អាចចាត់វិធានការអន្តរាគមន៍ផ្នែករដ្ឋបាល តាមស្ថានភាពជាក់ស្តែងនានា និងអាចធ្វើការនាំខ្លួនក្រុមក្មេងទំនើង ដែលបានធ្វើសកម្មភាពបង្កការអុកឡុកទាំងនោះ មកអង្គភាពរបស់ខ្លួន ដើម្បីធ្វើការអប់រំណែនាំដោយមានការចូលរួមទទួលខុសត្រូវពីឪពុក ម្តាយ ឬអាណាព្យាបាល ។

៣- ក្នុងករណីសកម្មភាពអុកឡុករបស់ក្មេងទំនើង បង្កើតបានជាបទល្មើសព្រហ្មទណ្ឌ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់នីតិវិធីនិងប្រើអំណាចតាមផ្លូវច្បាប់ ធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ដើម្បីបង្ក្រាបនិងកសាងសំណុំរឿងបញ្ជូនទៅអយ្យការ ដើម្បីចាត់ការជាសមត្ថកិច្ចតាមនីតិវិធីនៃច្បាប់ ។

៤- ក្រសួងទេសចរណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធមានសមត្ថកិច្ចចេញអាជ្ញាប័ណ្ណ ត្រូវដាក់ចេញនូវវិធានការណែនាំ និងហាមឃាត់ចំពោះការប្រមូលផ្តុំគ្នារបស់ក្មេងទំនើង នៅតាមផ្ទះសំណាក់ សណ្ឋាគារ ឬក្លិបកំសាន្ត ជាដើម ដើម្បីធ្វើសកម្មភាពល្មើសច្បាប់នានា ។ អ្នកគ្រប់គ្រង ផ្ទះសំណាក់ សណ្ឋាគារ ឬក្លិបកំសាន្ត ត្រូវសហការរាយការណ៍ជាបន្ទាន់ ដល់អាជ្ញាធរមានសមត្ថកិច្ច អំពីសកម្មភាពនៃក្រុមក្មេងទំនើង នៅក្នុងទីកន្លែងរបស់ខ្លួនគ្រប់គ្រង ។

៥- ដើម្បីធានារក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវដាក់ចេញនូវ វិធាន បញ្ញត្តិ ឬ បទបញ្ជាផ្នែករដ្ឋបាលចាំបាច់នានា តាមស្ថានភាពជាក់ស្តែង ជាពិសេស ត្រូវកំណត់ធ្វើការហាមឃាត់ នូវសកម្មភាពដែលជាមុខសញ្ញានាំទៅដល់ការប្រមូលផ្តុំគ្នាបង្កើតឱ្យមានជាក្រុមក្មេងទំនើង និងត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលនានា ឱ្យចូលរួមសហការ និងរាយការណ៍ផ្តល់ព័ត៌មានទាក់ទងនឹងសកម្មភាពនៃក្មេងទំនើងទាំងនេះ ។

៦- ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសចលនាឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅតាមសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេស លោកគ្រូ អ្នកគ្រូ ឪពុក ម្តាយ និងអាណាព្យាបាល ក្នុងការអប់រំណែនាំដល់កូនចៅ បងប្អូន សាច់ញាតិរបស់ខ្លួន សិស្សានុសិស្ស ឱ្យយល់ដឹងអំពីគ្រោះថ្នាក់នៃសកម្មភាពក្រុមក្មេងទំនើង ចៀសវាងការចូលរួម ឬប្រញាប់ដកខ្លួនចេញពីក្រុមនេះ ព្រមទាំងរាយការណ៍វែកមុខ អំពីមុខសញ្ញា និងសកម្មភាពរបស់ក្រុមក្មេងទំនើង ដល់អាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ ។

ទទួលបានសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួង ស្ថាប័នពាក់ព័ន្ធ និង គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវចាត់វិធានការអនុវត្តអោយមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-រាជធានី-ខេត្ត
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ